**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រដ្ឋបាលខេត្តបាត់ដំបង
លេខៈ ១៦៦៦ / សរណ / ២៦

ថ្ងៃព្រហស្បតិ៍ ...កើត ខែ អាសាឍ ឆ្នាំ មមី អដ្ឋស័ក ព.ស ២៥៧០
បាត់ដំបង, ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០២៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ និងមោឃភាពនៃប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ភូមិអង្រ្កង និងភូមិជួនទ្រី ឃុំព្រៃ ស្រុកមោងឫស្សី ខេត្តបាត់ដំបង

រដ្ឋបាលខេត្តបាត់ដំបងមានកិត្តិយស សូមជម្រាបជូនដំណឹងដល់ម្ចាស់ក្បាលដី ដែលមានក្បាលដីស្ថិតនៅក្នុងតំបន់វិនិច្ឆ័យ **ភូមិអង្រ្កង និងភូមិជួនទ្រី ឃុំព្រៃ ស្រុកមោងឫស្សី ខេត្តបាត់ដំបង** ឲ្យបានជ្រាបថា យោងតាមអនុក្រឹត្យលេខ៤៦អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ក្រោមដំណើរការនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបាត់ដំបង នឹងធ្វើការចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ (ប័ណ្ណកម្មសិទ្ធិ) ជូនដល់ម្ចាស់ក្បាលដី ដែលស្ថិតនៅក្នុងតំបន់វិនិច្ឆ័យខាងលើ នៅថ្ងៃទី២១......ខែ កក្កដា ឆ្នាំ២០២៦ខាងមុខនេះ។ ចំពោះប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លី(ប័ណ្ណស្លាបមាន់) ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ដែលចេញដោយរដ្ឋបាលសុរិយោដីកន្លងមកក្នុងតំបន់វិនិច្ឆ័យនេះ នឹងត្រូវអស់សុពលភាព តាមផ្លូវច្បាប់ ចាប់ពីថ្ងៃចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុខាងលើនេះតទៅ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមម្ចាស់ក្បាលដីស្ថិតនៅក្នុងទីតាំងខាងលើ ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លី ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុកន្លងមក មេត្តាយកប័ណ្ណទាំងនោះ មកប្រគល់ឲ្យមន្ត្រីរដ្ឋបាលសុរិយោដី ដើម្បីទទួលយកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុថ្មី ដែលនឹងត្រូវប្រគល់ជូនដោយមន្ត្រីរដ្ឋបាលសុរិយោដី នៅបរិវេណវត្តជួនទ្រីលិច...ភូមិជួនទ្រី....ឃុំព្រៃ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ចាប់ពី ថ្ងៃទី២១......ខែ កក្កដា.. ឆ្នាំ២០២៦... ជាកំហិត ។

ចំពោះម្ចាស់បំណុលដែលបានទទួលបញ្ចាំឬដាក់ធានា ពាក់ព័ន្ធនឹងក្បាលដីក្នុងតំបន់វិនិច្ឆ័យខាងលើ សូមយកប័ណ្ណទាំងអស់មកជូនមន្ត្រីរដ្ឋបាលសុរិយោដី ធ្វើនិយ័តកម្មដើម្បីធានាប្រាក់របស់លោកអ្នក ។

**អភិបាលខេត្ត**

**សុខ លូ**

ចម្លងជូន
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
  «ដើម្បីគោរពជូនជ្រាប»
- គណៈកម្មការរដ្ឋបាល
- កម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី
- មន្ទីរ.ដនសស.ខេត្តបាត់ដំបង
- រដ្ឋបាលស្រុកមោងឫស្សី
  «ដើម្បីជូនជ្រាប និង ជួយផ្សព្វផ្សាយ»
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋានៈ ផ្លូវលេខ០១, ទល់មុខស្ពានថ្មចាស់, ទូរស័ព្ទ និងទូរសារលេខៈ ០៥៣ ៧៣៩ ៩៩៩/ ៧៣៩ ៩៩៩ គេហទំព័រ: www.battambang.gov.kh
Address : Road 01, In front of old bridge, Telephone & Fax : 053 739 999 / 739 999 Website: www.battambang.gov.kh
អ៊ីម៉ែល / Email: info@battambang.gov.kh Facebook Page : រដ្ឋបាលខេត្តបាត់ដំបងៈ www.facebook.com/battambang.gov.kh